# សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦

## អង្គការសង្គមស៊ីវិលប្រកាសបើកយុទ្ធនាការ #ដោះលែងអ្នកទាំង៥ ដើម្បីគាំទ្របុគ្គលិកសមាគមអាដហុក និងមន្ត្រី គ.ជ.ប ដែលកំពុងជាប់ឃុំក្នុងពន្ធនាគារ

យើងខ្ញុំជាអង្គការសង្គមស៊ីវិលនិងអង្គការមិនមែនរដ្ឋាភិបាលដែលមានរាយនាមខាងក្រោម ចូលរួមបើកយុទ្ធនាការ #ដោះលែងអ្នកទាំង៥ នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ នេះ ដើម្បីគាំទ្រអ្នកការពារសិទ្ធិមនុស្សទាំងប្រាំនាក់ដែលកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ននិងក្រោមការស៊ើបអង្កេតរបស់តុលាការពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទសូកប៉ាន់។ អ្នកទាំងប្រាំប្រឈមនឹងការចោទប្រកាន់ទាក់ទងនឹងការផ្តល់ប្រឹក្សា និងការទូទាត់លើការចំណាយថ្លៃអាហារ និងថ្លៃធ្វើដំណើរដល់នារីម្នាក់ដែលត្រូវគេចោទថាមានទំនាក់ទំនងស្នេហាជាមួយលោក កឹម សុខា អនុប្រធានគណបក្សជំទាស់។ ការចោទប្រកាន់ទាំងអស់នោះគឺធ្វើឡើងក្រោមហេតុផលនយោបាយដែលនេះគឺជាការយាយីតាមផ្លូវច្បាប់។ បច្ចុប្បន្ននេះអ្នកការពារសិទ្ធិមនុស្សទាំងប្រាំនាក់បានជាប់ឃុំក្នុងពន្ធនាគារអស់រយៈពេលជាង ១០០ ថ្ងៃហើយ (មកទល់នឹងថ្ងៃទី០៨ ខែសីហានេះ គឺអស់រយៈពេល ១០២ ថ្ងៃ ហើយ)។

ជាផ្នែកមួយនៃយុទ្ធនាការ យើងខ្ញុំសូមអំពាវនាវដល់ប្រជាពលរដ្ឋដែលចាប់អារម្មណ៍ចូលរួមក្នុងយុទ្ធនាការនេះដើម្បីបង្ហាញការគាំទ្រដល់អ្នកទាំងប្រាំតាមរយៈផ្ញើសារនៅលើកាតប៉ុស្តាល់ជូនអ្នកការពារសិទ្ធិមនុស្សទាំងប្រាំនាក់ ដែលសារទាំងនោះយើងនឹងប្រមូល ហើយនាំយកទៅជូនអ្នកជាប់ឃុំទាំងប្រាំនាក់រហូតទាល់តែពួកគាត់ត្រូវបានដោះលែង។ ជាងនេះទៅទៀត យើងខ្ញុំនឹងចេញផ្សាយនូវកម្រងប័ណ្ណព័ត៌មានជាទៀងទាត់នៅលើបណ្តាញផ្សព្វផ្សាយសង្គមហ្វេសប៊ុក និង ធ្វីតទ័រ ដោយដាក់សញ្ញាហាសថែក #ដោះលែងអ្នកទាំង៥ ។ យុទ្ធនាការនេះគឺជាកិច្ចការបន្ថែមទៀតទៅលើកិច្ចការតស៊ូមតិដែលបានធ្វើឡើងនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ ដើម្បីស្វែងយល់ព័ត៌មានបន្ថែមអំពីយុទ្ធនាការនេះនិងពីរបៀបចូលរួម សូមមើល www.freethe5kh.net

ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សទាំងប្រាំនាក់នោះ បួននាក់ជាបុគ្គលិកជាន់ខ្ពស់របស់សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ("អាដហុក") ដែលរួមមាន លោក នី សុខា លោក យី សុខសាន្ត លោក ណៃ វ៉ងដា និងអ្នកស្រី លឹម មុនី និងលោក នី ចរិយា អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (អតីតបុគ្គលិករបស់សមាគមអាដហុក) ដែលត្រូវបានឃុំខ្លួននៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦។ នៅថ្ងៃទី០២ ខែឧសភា បុគ្គលិកសមាគមអាដហុកទាំងបួនរូបត្រូវបានចោទប្រកាន់ពីបទសូកប៉ាន់សាក្សី ហើយលោក នី ចរិយា ត្រូវបានចោទប្រកាន់ពីបទសមគំនិតក្នុងបទល្មើសដូចគ្នា។ លោក សឺន សាលី បុគ្គលិករបស់អង្គការសហប្រជាជាតិក៏ត្រូវបានចោទប្រកាន់ថាជាអ្នកសមគំនិតផងដែរ ប៉ុន្តែលោកនៅមានសេរីភាពដោយសារតែលោកមានអភ័យសិទ្ធិជាមន្ត្រីអង្គការសហប្រជាជាតិ។ នៅថ្ងៃដដែលនោះលោក នី ចរិយា ត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ ហើយបុគ្គលិកសមាគមអាដហុកទាំងបួនរូបត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារ

ព្រៃស។ សាលាឧទ្ធរណ៍បានបដិសេធសំណើសុំនៅក្រៅឃុំរបស់ពួកគាត់នៅថ្ងៃទី១៣ ខែមិថុនា។ បណ្តឹងសារទុក្ខជំទាស់ទៅនឹងសេចក្តីសម្រេចលើសំណើសុំនៅក្រៅឃុំ កំពុងបន្តទៅតុលាការកំពូល។

យុទ្ធនាការ #ដោះលែងអ្នកទាំង៥ ធ្វើឡើងក្នុងគោលបំណងប្រមូលការគាំទ្រចំពោះអ្នកការពារសិទ្ធិមនុស្សដែលកំពុងជាប់ឃុំទាំងប្រាំនាក់ដើម្បីរំលឹកពួកគាត់ថា សាធារណជនមិនបានបំភ្លេចចោលនូវបុព្វហេតុការពារសិទ្ធិមនុស្សរបស់ពួកគាត់ឡើយ និងបន្តចូលរួមលើកទឹកចិត្តពួកគាត់ឱ្យមានស្មារតីរឹងមាំស្របពេលដែលពួកគាត់កំពុងស្ថិតក្រោមការឃុំខ្លួន។

**សេចក្តីថ្លែងការណ៍រួមនេះគាំទ្រដោយ ៖**

១ អង្គការអាក់សិន អេតកម្ពុជា
២ ក្រុមការងារដើម្បីដោះស្រាយទំនាស់
៣ អង្គការលើកលែងទោសអន្តរជាតិ
៤ បណ្តាញលទ្ធិប្រជាធិបតេយ្យអាស៊ី
៥ វេទិកាអាស៊ីដើម្បីសិទ្ធិមនុស្ស និងការអភិវឌ្ឍ (FORUM-ASIA)
៦ តំណាងរាស្ត្រអាស៊ានដើម្បីសិទ្ធិមនុស្ស
៧ សហគមន៍បណ្តាញចតុមុខ
៨ អង្គការពលរដ្ឋសង្គ្រោះនាវា (Boat People SOS)
៩ អង្គការនៃភាពជាដៃគូភូមា (Burma Partnership)
១០ សហគមន៍បឹងកក់
១១ សហគមន៍បឹងត្របែក
១២ សហគមន៍បុរីកីឡា
១៣ អង្គការអនាគតយុវជនកម្ពុជាអាស៊ាន
១៤ សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា
១៥ អង្គការស្ម័គ្រចិត្តដើម្បីសង្គម
១៦ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
១៧ អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា
១៨ ទីភ្នាក់ងារអភិវឌ្ឍស្ត្រីកម្ពុជា
១៩ បណ្តាញយុវជនកម្ពុជា
២០ សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ
២១ អង្គការអ្នកការពារសិទ្ធិពលរដ្ឋ
២២ សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម
២៣ សម្ព័ន្ធសហគមន៍កសិករកម្ពុជា
២៤ គណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

២៥ មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
២៦ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
២៧ អង្គការសមធម៌កម្ពុជា
២៨ សហគមន៍បណ្ដាញអតីតស្ត្រីបឹងកក់
២៩ អង្គការអ្នកការពារឈានមុខ (Front Line Defender)
៣០ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
៣១ អង្គការមូលនិធិហែនរិច្ឆ ប៊ូល (Heinrich Böll Stiftung/Foundation)
៣២ ក្រុមការងារពិសេសសិទ្ធិលំនៅឋាន
៣៣ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch)
៣៤ សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
៣៥ យុវជនជនជាតិដើមភាគតិច ឃុំប្រមេរ ស្រុកត្បែងមានជ័យខេត្តព្រះវិហារ
៣៦ សមាគមឥន្ទ្រទេវី
៣៧ សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស ក្នុងក្របខ័ណ្ឌអង្កេតដើម្បីកិច្ចការពារដល់អ្នកការពារសិទ្ធិមនុស្ស
៣៨ សហគមន៍ជនជាតិដើមភាគតិចគួយ ឃុំប្រមេរ ខេត្តព្រះវិហារ
៣៩ សហគមន៍ដីធ្លី ភូមិគ្រួស ខេត្តបាត់ដំបង
៤០ សហគមន៍ដីធ្លី ភូមិស្ពុន ខេត្តសៀមរាប
៤១ សហគមន៍ដីធ្លី ភូមិព្រែកជីក ខេត្តកោះកុង
៤២ សហគមន៍ដីធ្លី ភូមិ១ សង្កាត់៣ ខេត្តព្រះសីហនុ
៤៣ សហគមន៍ដីធ្លី ឡពាង ខេត្តកំពង់ឆ្នាំង
៤៤ សហគមន៍ភ្នំបាត
៤៥ អង្គការពន្លកខ្មែរ
៤៦ សហគមន៍ផ្លូវរថភ្លើង ទួលសង្កែ A
៤៧ សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ
៤៨ សម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍
៤៩ អង្គការស្ដារកម្ពុជា
៥០ អង្គការស្ត្រីខ្មែរ
៥១ ជំនួយបរទេសសម្រាប់សហជីព (Unoin Aid Abroad-APHEDA)
៥២ អង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ក្នុងក្របខ័ណ្ឌអង្កេតដើម្បីកិច្ចការពារដល់អ្នកការពារសិទ្ធិមនុស្ស